ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ៖៧៨៥/១២-០៦-២០២១
សំណុំរឿងជំនុំជម្រះ
លេខ៖ ៧៩៥/១១-១១-២០២១
សាលក្រមព្រហ្មទណ្ឌ
លេខ៖៩៥៥"ក"/២១-១២-២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ត្រូវនឹងថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព-ស២៥៦៥ ប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ត្រូវនឹងថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព-ស២៥៦៥ ដែលមានសមាសភាពដូចតទៅ ៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តបាត់ដំបង

**ចៅក្រមប្រឹក្សា**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៨៥ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ មុខរបរ កម្មករ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបាត់ដំបង ពោះម៉ាយ មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) កម្រិតវប្បធម៌ថ្នាក់ទី៣ ប្រវត្តិនៃការផ្តន្ទាទោស ដោយតុលាការ ធ្លាប់ជាប់ពន្ធនាគាររយៈពេល០៣ខែ ករណី "ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៦០ ត-ព្រ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ។



Scanned with CamScanner

-ជាប់ចោទពីបទ " ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

២-ឈ្មោះ [redacted] សុភី ហៅ មុំ ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិអូរអំបិល ឃុំទឹកថ្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានទីលំនៅបច្ចុប្ប[redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) កម្រិតវប្បធម៌គ្មាន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥០២ ត-ព្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ។

៣-ឈ្មោះ [redacted] សុខខឿន ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិអូរអំបិល ឃុំទឹកថ្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានទីលំនៅបច្ចុប្ប[redacted] ពោះម៉ាយ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) កម្រិតវប្បធម៌គ្មាន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥០៤ ត-ព្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ។

៤-ឈ្មោ[redacted]យ៉ាន ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិអូរអំបិល ឃុំទឹកថ្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានទីលំនៅប[redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) កម្រិតវប្បធម៌គ្មាន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥០៣ ត-ព្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ។

-ជាប់ចោទពីបទ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

-លោកស្រី [redacted]យ៉ាណា អត្តលេខ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ជឿន ជនជាប់ចោទឈ្មោះ [redacted] សុភី ជនជាប់ចោទឈ្មោះ [redacted] សុខខឿន និងជនជាប់ចោទឈ្មោះ [redacted] យ៉ាន ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៦ ដស-សព ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាដំណោះស្រាយលេខ ៧២៧ ដ-ជ-រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៦៤៨៤ ត-ព្រ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។



Scanned with CamScanner

# ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

អញ្ញាតជននៅប្រទេសថៃបានផ្ញើកញ្ចប់គ្រឿងញៀន តាមក្រុមហ៊ុនដឹកជញ្ជូន ជេរិនធី មាន-ទីតាំងនៅភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។ ដោយមានការសង្ស័យលើកញ្ចប់ថាជាគ្រឿងញៀន ក្រុមហ៊ុនបានរាយការណ៍ទៅសមត្ថកិច្ចឱ្យឃ្លាំមើលអ្នកទទួលកញ្ចប់បញ្ញើនេះ ។ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ឈ្មោះ[redacted] ជឿន ភេទប្រុស អាយុ៣៦ឆ្នាំ បានមកទទួលកញ្ចប់បញ្ញើ ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងដកហូតគ្រឿងញៀន ចំនួន១៣៧១.២៧ក្រាម ម៉ូតូហុងដាឌ្រីម០១គ្រឿង ជារបស់ឈ្មោះ[redacted] សុភី ហៅ មុំ ទូរស័ព្ទដៃ០១គ្រឿង ជារបស់ឈ្មោះ [redacted] សុខឡឿន ជញ្ជីងថ្លឹងថ្នាំញៀន ចំនួន០១ រួមទាំងសម្ភារៈផ្សេងៗទៀត ជាវត្ថុតាងមានដូចក្នុងកំណត់ហេតុចាប់យក ផងដែរ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន បានសារភាពថា គ្រឿងញៀនទាំងនេះ គឺឈ្មោះ[redacted] សុភី ជាអ្នកទូរស័ព្ទបញ្ជាទិញពីជនមិនស្គាល់ឈ្មោះនៅប្រទេសថៃ ហើយប្រើឈ្មោះ [redacted] សុខឡឿន ឱ្យទៅទទួល តែត្រូវឈ្មោះ [redacted] សុខឡឿន ប្រើខ្លួនបន្ត ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ជឿន វត្តមាន ជនជាប់ចោទឈ្មោះ[redacted] សុភី អវត្តមាន ជនជាប់ចោទឈ្មោះ[redacted] សុខឡឿន អវត្តមាន ជនជាប់ចោទឈ្មោះ [redacted] យ៉ាន អវត្តមាន ។

-ជនជាប់ចោទឈ្មោះ [redacted] ជឿន បានឆ្លើយថា ៖ ឈ្មោះ [redacted] សុខឡឿន និងឈ្មោះ[redacted] សុភី បានប្រើខ្លួនឱ្យយកថ្នាំញៀនឱ្យគេ ដោយពួកគេសន្យាថាឱ្យប្រាក់មកខ្លួនចាយ ចំណែកឈ្មោះ [redacted] យ៉ាន ពុំមានពាក់ព័ន្ធក្នុងរឿងនេះទេ ។ ពួកគេមិនដែលប្រើខ្លួនឱ្យយកថ្នាំញៀនឱ្យគេទេ ពីមុនមក ។ តែនៅថ្ងៃកើតហេតុ ពួកគេបានប្រើខ្លួនឱ្យយកអីវ៉ាន់ឱ្យគេ តែខ្លួនមិនដឹងថាជាថ្នាំញៀន ទេ ។ ខ្លួនមិនទាន់បានឈ្នួលទេ ។

-ក្រឡាបញ្ជី ៖ អានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] ជឿន នៅសមត្ថកិច្ច ។

-ជនជាប់ចោទឈ្មោះ [redacted] ជឿន បានឆ្លើយថា ៖ អ្នកប្រើខ្លួនឱ្យយកអីវ៉ាន់ឱ្យគេនោះ គឺមិនទាន់និយាយថាឱ្យឈ្នួលប៉ុន្មានទេ ។ ក្រៅពីថ្នាំញៀន សមត្ថកិច្ចមិនបានដកហូតអ្វីពីខ្លួនទេ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ៖ ក្រោយពីបានពិនិត្យសំណុំរឿង និងឆ្លងតាមការសួរដេញដោលនាពេលសវនាការ រួចមក ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ជឿន បានឆ្លើយថាខ្លួនមិនបានដឹងថាអីវ៉ាន់ដែលផ្ញើមកឱ្យខ្លួននោះជាថ្នាំញៀន ឡើយ ដែលចម្លើយនេះ មិនមានមូលដ្ឋានច្បាស់លាស់ ឡើយ ។ ជនជាប់ចោទទាំងអស់បានធ្វើសកម្មភាពជាប្រព័ន្ធ ក្នុងការប្រព្រឹត្តបទល្មើសជួញដូរគ្រឿងញៀន ។ ដូច្នេះតំណាងអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ផ្តន្ទាទោសក្នុងកំរិតអតិបរមា និងចេញដីកាចាប់ខ្លួនលើជនជាប់ចោទផ្សេងៗទៀត ដែលអវត្តមាន ។

-មេធាវី [redacted]ម៉ាណា បានធ្វើសេចក្តីសន្និដ្ឋាន ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ រួចមក ឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ[redacted] ជឿន បានសារភាពថា បានត្រឹមតែយកកញ្ចប់អីវ៉ាន់ដែលគេប្រើ ដើម្បីយកទៅឱ្យគេបន្ត តែប៉ុណ្ណោះ ។ ចំពោះវត្ថុតាងដែលបានដកហូត គឺមានថ្នាំញៀនជាង១គីឡូក្រាម ។ ចំណែកជនជាប់ចោទផ្សេងៗទៀត បានគេចខ្លួនបាត់ពីមូលដ្ឋានអស់ហើយ ។



Scanned with CamScanner

ផ្ទះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងអស់ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា កំរិតនៃការផ្តន្ទាទោស ទៅតាមផ្លូវច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] ជឿន បាននិយាយសំដីចុងក្រោយថា ៖ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-តាមដីកាដំណោះស្រាយលេខ ៧២៧ ជ-ជ-រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង បានបញ្ជូនមកជំនុំជម្រះ លើជនជាប់ចោទឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ៣៦ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ និងជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ មុំ ភេទស្រី អាយុ២៨ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ជនជាប់ចោទឈ្មោះ [redacted] សុខឌឿន ភេទប្រុស អាយុ៣៣ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ជនជាប់ចោទឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ៣៥ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

-កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ នៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង មានករណី "ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន" មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ជឿន ភេទប្រុស ដោយមានបញ្ជាពីជនជាប់ចោទឈ្មោះ [redacted] សុខឌឿន និងឈ្មោះ [redacted] សុភី ភេទស្រី ដែលបានធ្វើសកម្មភាព "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ជាមួយអញ្ញាតជន នៅប្រទេសថៃ ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន នៅសមត្ថកិច្ច នៅអយ្យការ និងនៅចៅក្រមស៊ើបសួរ មានន័យប្រហាក់ប្រហែលគ្នាថា ៖ គ្រឿងញៀនទាំងនោះ ជារបស់ឈ្មោះ [redacted] សុភី ហៅ មុំ ជាអ្នកកម្មង់ទិញពីប្រទេសថៃ ឱ្យផ្ញើតាមក្រុមហ៊ុនដឹកជញ្ជូនជេអិនធី ហើយបានប្រើឱ្យឈ្មោះ [redacted] សុខឌឿន ឱ្យទៅយក ប៉ុន្តែឈ្មោះ [redacted] សុខឌឿន បានប្រើខ្លួនទៅជំនួសវិញ លុះពេលខ្លួនទៅយក ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន តែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ មុំ ជនជាប់ចោទឈ្មោះ [redacted] សុខឿន ជនជាប់ចោទឈ្មោះ [redacted] យ៉ាន បានគេចខ្លួនបាត់ពីមូលដ្ឋាន ដូច្នេះគ្មានភស្តុតាងណា អាចដោះបន្ទុកបានថា ជនជាប់ចោទរូបនេះ មិនបានប្រព្រឹត្តអំពើ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ឡើយ ។

-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន មានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងលទ្ធផលនៃការស៊ើបសួរ ដែលអាចកំណត់បានថា ៖ ជនជាប់ចោទឈ្មោះ [redacted] ជឿន ពិតជាបានប្រព្រឹត្តអំពើ " ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ចំណែកជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ មុំ ជនជាប់ចោទឈ្មោះ [redacted] សុខឿន និងជនជាប់ចោទឈ្មោះ [redacted] យ៉ាន ពិតជាបានប្រព្រឹត្តអំពើ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ប្រាកដមែន ។

-តាមកំណត់ហេតុទទួលវត្ថុតាង លេខ ៣៤១ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង ឃើញមាន ៖

១-ថ្នាំញៀនច្រកក្នុងស្រោមសំបុត្របិតជិត ចំនួន០១កញ្ចប់ ។

២-ទូរស័ព្ទដៃចំនួន០១គ្រឿង(ចាស់) ។

៣-ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ចំនួន០១គ្រឿង ។

៤-ម៉ូតូម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០១៨ ចំនួន០១គ្រឿង ។

៥-USB ផ្លាស ចំនួន០១ និងសម្ភារៈសម្រាប់ប្រើប្រាស់មួយចំនួន ។

-តាមកំណត់ហេតុ រាប់ ថ្លឹង និងដកសំណាកគ្រឿងញៀន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ ឃើញមាន ៖ ថ្នាំញៀនប្រភេទ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬ អាយ) ពណ៌ស ចំនួន០៦កញ្ចប់តូច និង០១កញ្ចប់ធំ មានទម្ងន់សាច់ថ្នាំសុទ្ធ ១.៣៤៥,២៩ក្រាម ដោយបានដកសំណាកចំនួន០៥កញ្ចប់ រួមមាន ដកសំណាកកញ្ចប់ទី០១ ទម្ងន់សាច់ថ្នាំសុទ្ធ២៣,១១ក្រាម ដកសំណាកកញ្ចប់ទី០២ ទម្ងន់សាច់ថ្នាំសុទ្ធ២៧,៥៩ក្រាម ដកសំណាកកញ្ចប់ទី០៣ ទម្ងន់សាច់ថ្នាំសុទ្ធ២៧,៥៣ក្រាម ដកសំណាកកញ្ចប់ទី០៤ ទម្ងន់សាច់ថ្នាំសុទ្ធ១៦,៩៤ក្រាម និងដកសំណាកកញ្ចប់ទី០៥ ទម្ងន់សាច់ថ្នាំសុទ្ធ១៥,៤៧ក្រាម សល់ក្នុងសំណុំរឿង ទម្ងន់សាច់ថ្នាំសុទ្ធ ១.២៣៤,៦៥ក្រាម ជារបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន ។

-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣២៦៥៩/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬ អាយ) ដែលមាន



Scanned with CamScanner

កម្រិតភាពសុទ្ធ ៧២.៣៤% វាស្ថិតក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ថ្នាំញៀនដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] ជឿន ជាប្រភេទមេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក) ទម្ងន់១.៣៤៥,២៩ក្រាម មានបរិមាណសារធាតុ មេតំហ្វេតាមីន ចំនួន ៧២.៣៤% ដូច្នេះ វាមានបរិមាណសុទ្ធ ចំនួន៩៧៣.១៨ក្រាម ។

-អំពើរបស់ជនជាប់ចោទដែលបានដឹកជញ្ជូន និងទិញលក់គ្រឿងញៀនដោយគ្មានការអនុញ្ញាត ជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ ពីបទ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-អំពើរបស់ជនជាប់ចោទ ស្តែងចេញពីចេតនាទុច្ចរិត ដោយដឹងថា អំពើលក់គ្រឿងញៀនជាអំពើខុសច្បាប់ តែពួកខ្លួននៅតែប្រព្រឹត្ត ដោយមានចេតនាបំពានលើច្បាប់ ។

-ជនជាប់ចោទខាងលើ ជានីតិជន និងជាសមត្ថជនដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ ។

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើ ៖ ឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ៣៦ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើ ៖ ឈ្មោះ [redacted] សុភី ហៅ មុំ ភេទស្រី អាយុ ២៨ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ឈ្មោះ [redacted] សុខឌឿន ភេទប្រុស អាយុ៣៣ឆ្នាំ (មានសាវតារជាតិដូចខាងលើ) និងឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ៣៥ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសដាក់ពន្ធនាគារ ៖ ឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ៣៦ឆ្នាំ (មានសាវតារជាតិដូចខាងលើ) រយៈពេល ៣០(សាមសិប)ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន និងពិន័យជាប្រាក់ចំនួន៤០,០០០,០០០(សែសិបលាន)រៀល បង់ចូលជាថវិការដ្ឋ ពីបទ " ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

២-ផ្តន្ទាទោសដាក់ពន្ធនាគារ ៖

២-១-ឈ្មោះ [redacted] សុភី ហៅ មុំ ភេទស្រី អាយុ២៨ឆ្នាំ (មានសាវតារជាតិដូចខាងលើ)

២-២-ឈ្មោះ [redacted] សុខឌឿន ភេទប្រុស អាយុ៣៣ឆ្នាំ (មានសាវតារជាតិដូចខាងលើ)



Scanned with CamScanner

២-៣-ឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ៣៥ឆ្នាំ (មានសាវតារជាតិដូចខាងលើ)

ក្នុងម្នាក់ៗរយៈពេល ៣០(សាមសិប)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបានយកមកអនុវត្តទោសក្នុងពន្ធនាគារ និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន៤០,០០០,០០០(សែសិបលាន)រៀល បង់ចូលជាថវិការដ្ឋ ពីបទ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងកាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

៣-វត្ថុតាង(ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២៥៩ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០២១ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង) រួមមាន ៖

៣-១-ថ្នាំញៀនក្រាមម្សៅប្រភេទ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬ អាយ) ទម្ងន់ ១.២៣៤,៦៥ក្រាម ជញ្ជីងចំនួន១គ្រឿង និងសម្ភារៈសម្រាប់ប្រើប្រាស់ថ្នាំញៀន ត្រូវរឹបអូសយកទៅបំផ្លាញចោល ។

៣-២-ម៉ូតូ ស៊េរីឆ្នាំ២០១៨ ចំនួន០១គ្រឿង និង ទូរស័ព្ទដៃ ចំនួន០១គ្រឿង(ចាស់) ត្រូវរឹបអូសចូលជាសម្បត្តិរដ្ឋ ។

៤-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ៖ ឈ្មោះ [redacted] សុភី ហៅ មុំ ឈ្មោះ [redacted] សុខខឿន និង ឈ្មោះ [redacted] យ៉ាន តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ត្រូវនឹងថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព-ស ២៥៦៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ត្រូវនឹងថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព-ស២៥៦៥ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជឿន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុភី ឈ្មោះ [redacted] សុខខឿន ឈ្មោះ [redacted] យ៉ាន ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |



Scanned with CamScanner